ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តក្រចេះ**

សាលក្រមរដ្ឋប្បវេណី
លេខ: ១០១ "ឈ"
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤
សំណុំរឿងរដ្ឋប្បវេណី
លេខ: ២៥
ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤

**បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ សាលក្រមប្រកាសជាសាធារណៈនាថ្ងៃទី០១ ខែសីហា ឆ្នាំ ២០២៤។**

-លោក [redacted]ក្រមសាលាដំបូងខេត្តក្រចេះ។
-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ។

**រវាងដើមចោទធនាគារ** [redacted] មាន អាស័យដ្ឋានស្ថិតនៅ[redacted]តំណាង ដោយលោក[redacted]**សម្បត្តិ** និងលោក [redacted]**វណ្ណៈ** មានតួនាទីជាអនុប្រធានឥណទានសាខា និងមាន អ្នកតំណាងដោយអាណត្តិគឺលោកមេធាវី [redacted]

**និងសហចុងចម្លើយឈ្មោះ** [redacted] **សារឿន** អាយុ ៦៤ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] **សាខន** អាយុ ៦៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅភូមិ[redacted]ដែល មានអ្នកតំណាងដោយអាណត្តិគឺលោកមេធាវី [redacted] មានអាស័យដ្ឋា[redacted]

**១.<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ</u>:** ប្តឹងសុំឲ្យតុលាការចេញសាល ក្រមសម្រេចបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសង នូវ:

១-១-កិច្ចសន្យាខ្ចីប្រាក់(ឥណទានខ្នាតមធ្យម)លេខ:LD១៧១៨៦០០៧៩០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧៖

ក-ទាមទារប្រាក់ដើមចំនួន USD ២០,៧៦៥.៤១(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)។

ខ-ទាមទារការប្រាក់ចំនួន USD ៤,៦៩៦.៥៤(បួនពាន់ប្រាំមួយរយកៅសិបប្រាំមួយដុល្លារអាមេរិក និងហាសិបបួនសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ (កាល បរិច្ឆេទសុពលភាពនៃកិច្ចសន្យាខ្ចីប្រាក់)។

គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិត ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។



Scanned with CamScanner

១-២-កិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៨៣១២០០៤៨៣ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨៖

ក-ទាមទារប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។

ខ-ទាមទារការប្រាក់ចំនួន 0.៩0%**ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-៣-កិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩៖

ក-ទាមទារប្រាក់ដើមចំនួន USD **២១,៦១៩.៦៦**(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)។

ខ-ទាមទារការប្រាក់ចំនួន **១%ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

២-ទាមទារសេវាពិគ្រោះផ្លូវច្បាប់, ការខាតបង់ពេលវេលា និងប្រាក់ជំងឺចិត្តចំនួន USD ៥,000.00 (ប្រាំពាន់ដុល្លារអាមេរិកគត់)។

៣-ចេញសាលក្រមដែលអាចយកទៅអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុចទី១-១-ក, ១-២-ក និង ១-៣-ក។

៤-បង្គាប់ឲ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

### ២-<u>អង្គហេតុ</u>

-ក្នុងរឿងក្ដីនេះ គឺសហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted]សាខន បានរួមគ្នាខ្ចីប្រាក់ពីធនាគារ [redacted] ចំនួន០៣លើក ដោយលើកទី០១គឺ៖ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ នូវទឹកប្រាក់ចំនួន USD ៣១,000.00(សាមសិបមួយពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ១០,០៣៤.៥៩(ដប់ពាន់សាមសិបបួនដុល្លារអាមេរិក និងហាសិបប្រាំបួនសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២០,៩៦៥.៤១(ម្ភៃពាន់ប្រាំបួនរយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD



Scanned with CamScanner

២០០.០០(ពីររយដុល្លារអាមេរិកគត់)។ លើកទី២គឺ៖ កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចុងចម្លើយបានខ្ចីប្រាក់ដើមពីដើមចោទចំនួន USD ៤៣,០០០.០០(សែសិបបីពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ៥,៣៨៥.៨២(ប្រាំពាន់បីរយប៉ែតសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបពីរសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។ លើកទី៣គឺ៖ កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ សហចុងចម្លើយបានខ្ចីប្រាក់ដើមពីដើមចោទចំនួន USD ២៤,០០០.០០(ម្ភៃបួនពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ២,១៣២.៥០(ពីរពាន់មួយរយសាមសិបពីរដុល្លារអាមេរិក និងហាសិបសេន)។ លុះក្រោយមក សហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២១,៨៦៧.៥០(ម្ភៃមួយពាន់ប្រាំបីរយហុកសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD ២៤៧.៨៤(ពីររយសែសិបប្រាំពីរដុល្លារអាមេរិក និងប៉ែតសិបបួនសេន)។ ក្រោយមកកាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដោយសារការប៉ះពាល់នៃការរីករាលដាលនៃវីរុសកូវីដ១៩ សហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] សាខន បានដាក់ពាក្យស្នើសុំឥណទានឡើងវិញលើកកិច្ចសន្យាខ្ចីប្រាក់ទាំង០៣ខាងលើ ហើយខាង**ធនាគារ** [redacted] បានទទួលសំណើ និងបានរៀបចំឥណទានជូនតាមសំណើរ ដោយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ សហចុងចម្លើយបានព្រមព្រៀងលើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ និងកិច្ចព្រមព្រៀងបន្ថែម។ បន្ទាប់មក នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ដើមចោទ**ធនាគារ** [redacted] បានចេញតារាងបង់ប្រាក់ថ្មីចំនួន០៣ ជូនឱ្យសហចុងចម្លើយ ដោយបានកែប្រែលើរបៀបសងប្រាក់ថ្មី និងលេខកិច្ចសន្យាខ្ចីប្រាក់ថ្មី គឺកិច្ចសន្យាខ្ចីប្រាក់លេខLD១៧១៨៦០០៧៩០ ប្តូរទៅ LD២០២៨៨០១០៩៤, កិច្ចសន្យាខ្ចីប្រាក់លេខLD១៨៣១២០០៤៨៣ ប្តូរទៅលេខLD២០២៨៨០១១៥៤ និងកិច្ចសន្យាខ្ចីប្រាក់លេខLD១៩៣០៩០០២៩៩ ប្តូរទៅលេខLD២០២៨៨០១១៦៦។ ដូច្នេះ សហចុងចម្លើយនៅជំពាក់ប្រាក់ដើមលើកទី០១ចំនួន USD **២០,៧៦៥.៤១**(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) និងការប្រាក់ចំនួន: **USD ៤,៦៩៦.៥៤**(បួនពាន់ប្រាំមួយរយកៅ សិបប្រាំមួយដុល្លារអាមេរិក និងហាសិបបួនសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ (កាលបរិច្ឆេទសុពលភាពនៃកិច្ចសន្យាខ្ចីប្រាក់) និងប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។ លើកទី០២ចំនួន USD **៣៧,៦១៤.១៨** (សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) និងការប្រាក់ចំនួន**០.៩០%ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី១២ ខែ

មករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន និងប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។ លើកទី០៣ ចំនួន USD **២១,៦១៩.៦៦**(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) និងការប្រាក់ចំនួន **១%ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន និងប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

៣-**សេចក្តីថ្លែងការណ៍របស់គូភាគី**

៣.១-តំណាងឲ្យដើមចោទៈ [redacted] គឺលោក [redacted]ណ្ណៈ បានថ្លែងការណ៍ថាៈ មូលហេតុដែលខ្ញុំប្តឹងទាមទារពីសហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] សាខន ដោយហេតុថាៈ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ សហចុងចម្លើយបានខ្ចីប្រាក់ដើមពីដើមចោទចំនួន USD **៣១,០០០.០០**(សាមសិបមួយពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD **១០,០៣៤.៥៩**(ដប់ពាន់សាមសិបបួនដុល្លារអាមេរិក និងហាសិបប្រាំបួនសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD **២០,៩៦៥.៤១**(ម្ភៃពាន់ប្រាំបួនរយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD **២០០.០០**(ពីររយដុល្លារអាមេរិកគត់) រួចហើយក៏ខកខានសងប្រាក់ដើមមកធនាគាររហូតមក ទោះបីជាធនាគារបានធ្វើការជូនដំណឹងឲ្យសងប្រាក់រួចហើយក្តី ក៏សហចុងចម្លើយនៅតែមិនព្រមសងប្រាក់ដែរ យោងតាមកិច្ចសន្យាខ្ចីប្រាក់(ឥណទានខ្នាតមធ្យម) លេខៈ **LD១៧១៨៦០០៧៨០** ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧។ បន្ទាប់មក នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចុងចម្លើយបានខ្ចីប្រាក់ដើមពីដើមចោទចំនួន USD **៤៣,០០០.០០**(សែសិបបីពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD **៥,៣៨៥.៨២**(ប្រាំពាន់បីរយប៉ែតសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបពីរសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD **៣៧,៦១៤.១៨**(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) រួចហើយក៏ខកខានសងប្រាក់ដើមមកធនាគាររហូតមក ទោះបីជាធនាគារបានធ្វើការជូនដំណឹងឲ្យសងប្រាក់រួចហើយក្តី ក៏សហចុងចម្លើយនៅតែមិនព្រមសងប្រាក់ដែរ យោងតាមកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខៈ LD១៨៣១២០០៤៨៣ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ក្រោយមកនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ សហចុងចម្លើយបានខ្ចីប្រាក់ដើមពីដើមចោទចំនួន USD **២៤,០០០.០០**(ម្ភៃបួនពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន **USD ២,១៣២.៥០**(ពីរពាន់មួយរយសាមសិបពីរដុល្លារអាមេរិក និងហាសិបសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើ



Scanned with CamScanner

វិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD **២១,៨៦៧.៥០** (ម្ភៃមួយពាន់ប្រាំបីរយហុកសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀត ដែលមានចំនួន USD **២៤៧.៨៤**(ពីររយសែសិបប្រាំពីរដុល្លារអាមេរិក និងប៉ែតសិបបួនសេន) រួចហើយក៏ខកខានសងប្រាក់ដើមមកធនាគាររហូតមក ទោះបីជាធនាគារបានធ្វើការជូនដំណឹងឱ្យសងប្រាក់រួចហើយក្តី ក៏សហចុងចម្លើយនៅតែមិនព្រមសងប្រាក់ដែរ យោងតាមកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

<u>សំណូមពរ:</u> ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចបង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសង នូវ:

១-១-ក-ទាមទារប្រាក់ដើមចំនួន USD **២០,៧៦៥.៤១** (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)។

១-១-ខ-ទាមទារការប្រាក់ចំនួន USD **៤,៦៩៦.៥៤** (បួនពាន់ប្រាំមួយរយកៅសិបប្រាំមួយដុល្លារអាមេរិក និងហាសិបបួនសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ (កាលបរិច្ឆេទសុពលភាពនៃកិច្ចសន្យាខ្ចីប្រាក់)។

១-១-គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-២-ក-ទាមទារប្រាក់ដើមចំនួន USD **៣៧,៦១៤.១៨** (សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។

១-២-ខ-ទាមទារការប្រាក់ចំនួន **0.៩0%ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-២-គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-៣-ក-ទាមទារប្រាក់ដើមចំនួន USD **២១,៦១៩.៦៦** (ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)។

១-៣-ខ-ទាមទារការប្រាក់ចំនួន **១%ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-៣-គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

២-ទាមទារសេវាពិគ្រោះផ្លូវច្បាប់, ការខាតបង់ពេលវេលា និងប្រាក់ជំងឺចិត្តចំនួន USD ៥,000.00 (ប្រាំពាន់ដុល្លារអាមេរិកគត់)។



Scanned with CamScanner

៣-ចេញសាលក្រមដែលអាចយកទៅអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុចទី១-១-ក, ១-២-ក និង ១-៣-ក។

៤-បង្គាប់ឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

-ចំពោះការស្នើសុំលើកលែងខាងលើ និងសុំពន្យាពេលចំនួន៥(ប្រាំ)ខែនោះ គឺខាងធនាគារ [redacted] មិនឯកភាពទេ។

៣.២-អ្នកតំណាងឱ្យដើមចោទ: ធនាគារ [redacted] គឺលោក [redacted] សម្បត្តិ បានថ្លែងការណ៍ថា: ខ្ញុំឯកភាពតាមសេចក្ដីថ្លែងការណ៍របស់លោក [redacted] វណ្ណៈ ទាំងស្រុង ហើយចំពោះតារាងបង់ប្រាក់គឺមានចំនួន៣ ដោយតារាងទី១ បានដល់កាលបរិច្ឆេទបញ្ចប់នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣។ ចំពោះតារាងបង់ប្រាក់ទី២ និងតារាងបង់ប្រាក់ទី៣ គឺមិនទាន់ដល់កាលបរិច្ឆេទបញ្ចប់ទេ។ ចំពោះប្រាក់ពិន័យ២៤ភាគក្នុងមួយឆ្នាំ គឺជាប្រាក់យឺតយ៉ាវរបស់អតិថិជន។ ចំពោះការគិតការប្រាក់ គឺគិតចាប់ពីថ្ងៃយឺតយ៉ាវរហូតដល់ថ្ងៃសងគ្រប់ចំនួន ឬការបរិច្ឆេទបញ្ចប់នៃតារាងបង់ប្រាក់។

៣.៣-អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ: ធនាគារ [redacted] គឺលោកមេធាវី [redacted] បានថ្លែងការណ៍ថា: ខ្ញុំសូមទាមទារឱ្យសហចុងចម្លើយសងដូចខាងក្រោម:

១-១-ក-ទាមទារប្រាក់ដើមចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)។

១-១-ខ-ទាមទារការប្រាក់ចំនួន USD ៤,៦៩១.៥៤ (បួនពាន់ប្រាំមួយរយកៅសិបប្រាំមួយដុល្លារអាមេរិក និងហាសិបបួនសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ (កាលបរិច្ឆេទសុពលភាពនៃកិច្ចសន្យាខ្ចីប្រាក់)។

១-១-គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-២-ក-ទាមទារប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨ (សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។

១-២-ខ-ទាមទារការប្រាក់ចំនួន ០.៩០%**ក្នុងមួយខែ** លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-២-គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-៣-ក-ទាមទារប្រាក់ដើមចំនួន USD ២១,៦១៩.៦៦ (ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)។



Scanned with CamScanner

១-៣-ខ-ទាមទារការប្រាក់ចំនួន ១%ក្នុងមួយខែ លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-៣-គ-ទាមទារប្រាក់ពិន័យចំនួន ២៤%ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

២-ទាមទារសេវាពិគ្រោះផ្លូវច្បាប់, ការខាតបង់ពេលវេលា និងប្រាក់ជំងឺចិត្តចំនួន USD ៥,000.00 (ប្រាំពាន់ដុល្លារអាមេរិកគត់)។

៣-ចេញសាលក្រមដែលអាចយកទៅអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុចទី១-១-ក, ១-២-ក និង ១-៣-ក។

៤-បង្គាប់ឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

៣.៤-សហចុងចម្លើយឈ្មោះ [redacted] សារឿន បានថ្លែងការណ៍ថា៖ ខ្ញុំ និងប្រពន្ធឈ្មោះ [redacted] សាខន គឺពិតជា បានខ្ចីប្រាក់ពី ធនាគារ [redacted] ចំនួន០៣លើក ដោយលើកទីមួយ៖ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ ចំនួន USD ៣១,000.00(សាមសិបមួយពាន់ដុល្លារអាមេរិក) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ១០,០៣៤.៥៩(ដប់ពាន់សាមសិបបួនដុល្លារអាមេរិក និងហាសិបប្រាំបួនសេន)។ លុះក្រោយមកខ្ញុំបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២០,៩៦៥.៤១ (ម្ភៃពាន់ប្រាំបួនរយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD ២00.00 (ពីររយដុល្លារអាមេរិកគត់) រួចហើយក៏ខកខានសងប្រាក់ដើមមកធនាគាររហូតមក។ ដូច្នេះ ខ្ញុំ និងប្រពន្ធនៅជំពាក់ប្រាក់ដើមធនាគារ [redacted] ចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន), ការប្រាក់ ចំនួន USD ៤,៦៩៦.៥៤ (បួនពាន់ប្រាំមួយរយកៅសិបប្រាំមួយដុល្លារអាមេរិក និងហាសិបបួនសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ និងប្រាក់ពិន័យចំនួន២៤%ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសងគិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១។ លើកទីពីរ៖ កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ខ្ញុំ និង ប្រពន្ធពិតជាបានខ្ចីប្រាក់ពីធនាគារ [redacted] ចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។ លុះក្រោយមកខ្ញុំបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) រួចហើយក៏ខកខានសងប្រាក់ដើមមកធនាគាររហូតមក។ ដូច្នេះ ខ្ញុំ និងប្រពន្ធនៅជំពាក់ប្រាក់ដើមធនាគារ [redacted] ចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន), ការប្រាក់ចំនួន0.៩០% ក្នុងមួយខែ លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ និងប្រាក់ពិន័យចំនួន២៤%ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិន



Scanned with CamScanner

បានសង គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។ និងលើកទី៣៖ កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ខ្ញុំ និងប្រពន្ធពិតជាបានខ្ចីប្រាក់ពីធនាគា[redacted] ចំនួន USD ២៤,០០០.០០(ម្ភៃបួនពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ២,១៣២.៥០(ពីរពាន់មួយរយសាមសិបពីរដុល្លារអាមេរិក និងហាសិបសេន)។ លុះក្រោយមកខ្ញុំបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២១,៨៦៧.៥០(ម្ភៃមួយពាន់ប្រាំបីរយហុកសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD ២៤៧.៨៤ (ពីររយសែសិបប្រាំពីរដុល្លារអាមេរិក និងប៉ែតសិបបួនសេន) រួចហើយក៏ខកខានសងប្រាក់ដើមមកធនាគាររហូតមក។ ដូច្នេះ ខ្ញុំ និងប្រពន្ធនៅជំពាក់ប្រាក់ដើមធនាគារ[redacted] ចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន), ការប្រាក់ចំនួន ១%ក្នុងមួយខែ លើប្រាក់ដើមដែលនៅជំពាក់ គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ និងប្រាក់ពិន័យចំនួន ២៤%ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១។ ខ្ញុំទទួលស្គាល់ការប្តឹងទាមទារលើប្រាក់ដើម, ការប្រាក់ និងប្រាក់ពិន័យ ប៉ុន្តែខ្ញុំមិនទទួលស្គាល់ការប្តឹងទាមទារផ្សេងទៀតរបស់តំណាងឱ្យដើមចោទនោះទេ ហើយខ្ញុំសូមថ្លែងការណ៍តបបន្ថែមទៀតថា: ខ្ញុំឯកភាពតាមការប្តឹងទាមទាររបស់ដើមចោទធនាគារ[redacted] ប៉ុន្តែខ្ញុំសុំឱ្យធនាគា[redacted] ធ្វើតារាងប្រាក់ដែលខ្ញុំនៅជំពាក់ទាំង០៣លើក និងតារាងប្រាក់ដែលខ្ញុំបានសង ព្រមទាំងតារាងការប្រាក់ដែលបានសង និងនៅជំពាក់ ហើយខ្ញុំសុំឱ្យធនាគារ[redacted] លើកលែងនូវប្រាក់ពិន័យ ប្រាក់ថ្លៃវាកម្មច្បាប់ ឬសំណងជំងឺចិត្ត និងប្រាក់ប្រដាប់ក្តី។

សំណូមពរ: ខ្ញុំសុំធនាគា[redacted] ពន្យាពេលឱ្យខ្ញុំចំនួន៥(ប្រាំ)ខែ ដើម្បីខ្ញុំអាចរកប្រាក់មកសងឱ្យធនាគារឱ្យគ្រប់ចំនួន ហើយខ្ញុំសុំឱ្យដើមចោទលើកលែងការប្រាក់ ប្រាក់ពិន័យ និងប្រាក់សំណងជំងឺចិត្ត ហើយចំពោះប្រាក់ដើមគឺខ្ញុំសូមទទួលស្គាល់។

៣.៥-អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយគឺលោក [redacted] បានថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្ញុំឃើញថាការទាមទារលើការប្រាក់ផង និងប្រាក់ពិន័យផង គឺជាការទាមទារជាន់គ្នា ហើយខ្ញុំសូមឱ្យលោកចៅក្រមពិចារណាលើកាលបរិច្ឆេទលើការទាមទារការប្រាក់ និងប្រាក់ពិន័យ។ ចំពោះលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺខ្ញុំឯកភាពតាមការទទួលស្គាល់របស់កូនក្តីរបស់ខ្ញុំទាំងស្រុង។ ខ្ញុំឃើញថាប្រាក់ដែលកូនក្តីរបស់ខ្ញុំបានបង់កន្លងមករហូតដល់ពេលដែលគាត់ខកខានក្នុងការបង់ គឺខាងដើមចោទមិនបានបញ្ជាក់ឱ្យកូនក្តីនោះទេ។ ខ្ញុំសូមជូនសេចក្តីថ្លែងការណ៍តាមក្រោយ ហើយខ្ញុំឃើញកូនក្តីរបស់ខ្ញុំបានសុំឱ្យដើមចោទផ្តល់តារាងសងប្រាក់ និងតារាងប្រាក់ដែលសល់។ ចំពោះការទាមទារលើប្រាក់ដើម គឺកូនក្តីរបស់ខ្ញុំទទួលស្គាល់ហើយ ប៉ុន្តែខ្ញុំសូមច្រានចោល

ការទាមទារត្រង់ចំណុចទី២, ទី៣ និងទី៤។

**៤-ការពិនិត្យភស្តុតាង៖**

-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានខ្នាតមធ្យម)លេខ: LD១៧១៨៦០០៧៨០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧។

-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតតូច) លេខ: LD១៨៣១២០០៤៨៣ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតតូច) លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

-កាលវិភាគសងប្រាក់ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ (ចំនួន០៣តារាង)។

-កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១០០៥០១០៩-០៧៦៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១០០៥០១០៩-០៧៧៤ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣។

-តារាងសង្ខេបស្ដីពីចំនួនទឹកប្រាក់ដែលនៅជំពាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤។

-លិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសងប្រាក់ដែលយឺតយ៉ាវមក ធនាគារ [redacted] ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។

**៥-ចំណុចវិវាទ:**

-លើកទីមួយតើចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមចំនួន USD ២០,៧៦៥.៤១(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)ដែរឬទេ?

-លើកទីពីរតើចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)?

-លើកទីបីតើចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)?

## ការសំអាងហេតុ

**ឆ្លងកាត់តាមនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់**

**និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ យល់ឃើញថា៖**

**ក-ការវិនិច្ឆ័យចំពោះការទាមទារប្រាក់ដើមលើកទី១៖**

**ក.១-ការទទួលស្គាល់អង្គហេតុ៖**

-ដើមចោទ និងសហចុងចម្លើយទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ (ឥណទានខ្នាតមធ្យម) លេខ: LD១៧១៨៦០០៧៨០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ នូវប្រាក់កម្ចីចំនួន USD ៣១,000.00 (សាមសិបមួយពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ១០,០៣៤.៥៩



Scanned with CamScanner

(ដប់ពាន់សាមសិបបួនដុល្លារអាមេរិក និងហាសិបប្រាំបួនសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២០,៩៦៥.៤១ (ម្ភៃពាន់ប្រាំបួនរយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD ២០០.០០(ពីររយដុល្លារអាមេរិកគត់) ប្រាកដមែន។ ក្នុងនោះសហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] សាខន ពិតជានៅជំពាក់ប្រាក់ដើមចោទធនាគារ [redacted] ចំនួន USD ២០,៧៦៥.៤១(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) ដែលមិនទាន់បានសង។

**ក.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច ក.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ធ្វើឡើងស្របតាមបញ្ញត្តិមាត្រា៥៧៩ និងមាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណី។ ភាគីទាំងពីរក៏បានទទួលស្គាល់ថា សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទ នូវប្រាក់ដើមចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និង សែសិបមួយសេន) ដោយសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលជាហេតុនាំឱ្យដើមចោទធ្វើការទាមទារប្រាក់ដើម ដោយផ្អែកតាមការរំលាយកិច្ចសន្យា។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយសងប្រាក់ចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) ទៅឱ្យដើមចោទ ស្របតាមបញ្ញត្តិមាត្រា៤០៨ និងមាត្រា៤១១ នៃក្រមរដ្ឋប្បវេណី។

**ខ-ការវិនិច្ឆ័យអំពីការប្រាក់លើកទី១៖**

**ខ.១-ការទទួលស្គាល់អង្គហេតុ៖**

-ដើមចោទ និងសហចុងចម្លើយទទួលស្គាល់ថា ពិតជាបង្កើតកិច្ចសន្យាខ្ចីប្រាក់ (ឥណទានខ្នាតមធ្យម) លេខ: LD១៧១៨៦០០៧៩០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ និងបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២០,៧៦៥.៤១(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) ដោយមានភ្ជាប់ការប្រាក់ចំនួន ១,១%(មួយក្បៀសមួយភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)។ ក្នុងនោះដែរភាគីទាំងពីរក៏បានទទួលស្គាល់ថា ក្រោយពីបង្កើតកិច្ចសន្យាខ្ចីប្រាក់ទាំងនេះរួចមក សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចបង់ការប្រាក់ទៅឱ្យដើមចោទ គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣។

**ខ.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច ខ.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ និងដោយមានភ្ជាប់ការប្រាក់ក្នុងអត្រាចំនួន ១,១%



Scanned with CamScanner

(មួយក្បៀសមួយភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD **២០,៧៦៥.៤១** (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)។ ការកំណត់អត្រាការប្រាក់នេះ គឺស្របតាមប្រការ ១ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ចេញដោយក្រសួងយុត្តិធម៌ ស្តីអំពីការប្រាក់ដែលត្រូវបានកម្រិតមិនត្រូវឱ្យលើសពីចំនួន១៨%(ដប់ប្រាំបីភាគរយ) ក្នុង១(មួយ)ឆ្នាំ ឬ១,៥%(មួយក្បៀសប្រាំភាគរយ) ក្នុង១(មួយ)ខែ ដែលគប្បីតុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ទៅតាមការព្រមព្រៀងរបស់គូភាគី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយបង់សងការប្រាក់ក្នុងអត្រាចំនួន ១,១% (មួយក្បៀសមួយភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD **២០,៧៦៥.៤១** (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ ទៅឱ្យដើមចោទ។

**គ-ការវិនិច្ឆ័យអំពីប្រាក់ពិន័យ៖**

**គ.១-ការទទួលស្គាល់អង្គហេតុ៖**

ដើមចោទ និងសហចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានខ្នាតមធ្យម) លេខ: **LD១៧១៨៦០០៧៩០** ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ នូវប្រាក់កម្ចីចំនួន USD **៣១,000.00** (សាមសិបមួយពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD **១០,០៣៤.៥៩** (ដប់ពាន់សាមសិបបួនដុល្លារអាមេរិក និងហាសិបប្រាំបួនសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD **២០,៩៦៥.៤១**(ម្ភៃពាន់ប្រាំបួនរយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀតដែលមានចំនួន USD **២00.00**(ពីររយដុល្លារអាមេរិកគត់) ដោយបានកំណត់អត្រាការប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ នៃប្រាក់ដើមចំនួន USD **២០,៧៦៥.៤១** (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) ផ្អែកតាមតារាងកាលវិភាគបង់ប្រាក់ ហើយត្រូវគណនាតាមចំនួនថ្ងៃដែលបានខកខាន។ ក្រោយពីបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ទាំងនេះរួចមក សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ទៅឱ្យដើមចោទតាមការកំណត់នូវប្រាក់ដើម និងការប្រាក់ គិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

**គ.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច គ.១ ខាងលើ តុលាការទទួលស្គាល់ថាដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ដោយកំណត់អត្រាការប្រាក់ពិន័យក្នុងអត្រាចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ ក្នុងករណីដែលសហចុងចម្លើយបានយឺតយ៉ាវបង់សងប្រាក់ដើម និងការមកឱ្យដើមចោទ។ ការកំណត់នេះដែរ គឺស្របតាមប្រការ ២ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះ

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ចេញដោយក្រសួងយុត្តិធម៌ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតមិនត្រូវឱ្យលើសពីចំនួន២៧%(ម្ភៃប្រាំពីរភាគរយ) ក្នុង១(មួយ)ឆ្នាំ ឬស្មើនឹងចំនួន២,២៥%(ពីរក្បៀសម្ភៃប្រាំភាគរយ) ក្នុង១(មួយ)ខែ ដែលគប្បីតុលាការទទួលស្គាល់ការកំណត់អត្រាប្រាក់ពិន័យចំនួន២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយបង់សងអត្រាការប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ នៃប្រាក់ដើមចំនួន USD ២០,៧៦៥.៤១(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) ផ្អែកតាមតារាងវិភាគបង់ប្រាក់ ហើយត្រូវគណនាតាមចំនួនថ្ងៃដែលបានខកខានទៅឱ្យដើមចោទតាមការទាមទារ ដោយគិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

**ក-ការវិនិច្ឆ័យចំពោះការទាមទារប្រាក់ដើមលើកទី២៖**

**ក.១-ការទទួលស្គាល់អង្គហេតុ៖**

-ដើមចោទ និងសហចុងចម្លើយទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៨៣១២០០៤៨៣ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នូវប្រាក់កម្ចីចំនួន USD ៤៣,000.00(សែសិបបីពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD ៥,៣៨៥.៨២(ប្រាំពាន់បីរយប៉ែតសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបពីរសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ប្រាកដមែន។ ក្នុងនោះសហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] សាខន ពិតជានៅជំពាក់ប្រាក់ដើមចោទធនាគារ [redacted] ចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ដែលមិនទាន់បានសង។

**ក.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច ក.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ធ្វើឡើងស្របតាមបញ្ញត្តិមាត្រា៥៧៩ និងមាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណី។ ភាគីទាំងពីរក៏បានទទួលស្គាល់ថា សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទ នូវប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ដោយសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលជាហេតុនាំឱ្យដើមចោទធ្វើការទាមទារប្រាក់ដើម ដោយផ្អែកតាមការរំលាយកិច្ចសន្យា។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយសងប្រាក់ចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ទៅឱ្យដើមចោទ ស្របតាមបញ្ញត្តិមាត្រា៤០៨ និងមាត្រា៤១១ នៃក្រមរដ្ឋប្បវេណី។

**ខ-ការវិនិច្ឆ័យអំពីការប្រាក់លើកទី២៖**



Scanned with CamScanner

## ខ.១-ការទទួលស្គាល់អង្គហេតុៈ

ដើមចោទ និងសហចុងចម្លើយទទួលស្គាល់ថា ពិតជាបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: **LD១៨៣១២០០៤៨៣** ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នូវប្រាក់កម្ចីចំនួន USD **៤៣,000.00** (សែសិបបីពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD **៥,៣៨៥.៨២**(ប្រាំពាន់បីរយប៉ែតសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបពីរសេន) និងបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD **៣៧,៦១៤.១៨**(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ដោយមានភ្ជាប់ការប្រាក់ចំនួនៈ 0,៩0% (សូន្យក្បៀសកៅសិបភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD **៣៧,៦១៤.១៨**(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។ ក្នុងនោះដែរភាគីទាំងពីរក៏បានទទួលស្គាល់ថា ក្រោយពីបង្កើតកិច្ចសន្យាខ្ចីប្រាក់ទាំងនេះរួចមក សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចបង់ការប្រាក់ទៅឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

## ខ.២-សេចក្តីសន្និដ្ឋានៈ

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច ខ.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ និងដោយមានភ្ជាប់ការប្រាក់ក្នុងអត្រាចំនួន 0,៩0% (សូន្យក្បៀសកៅសិបភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD **៣៧,៦១៤.១៨**(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។ ការកំណត់អត្រាការប្រាក់នេះ គឺស្របតាមប្រការ ១ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ចេញដោយក្រសួងយុត្តិធម៌ ស្តីអំពីការប្រាក់ដែលត្រូវបានកម្រិតមិនត្រូវឱ្យលើសពីចំនួន១៨%(ដប់ប្រាំបីភាគរយ) ក្នុង១(មួយ)ឆ្នាំ ឬ១,៥%(មួយក្បៀសប្រាំភាគរយ) ក្នុង១(មួយ)ខែ ដែលគប្បីតុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ទៅតាមការព្រមព្រៀងរបស់គូភាគី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយបង់សងការប្រាក់ក្នុងអត្រាចំនួន 0,៩0% (សូន្យក្បៀសកៅ សិបភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD **៣៧,៦១៤.១៨**(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន ទៅឱ្យដើមចោទ។

## គ-ការវិនិច្ឆ័យអំពីប្រាក់ពិន័យលើកទី២ៈ

## គ.១-ការទទួលស្គាល់អង្គហេតុៈ

ដើមចោទ និងសហចុងចម្លើយហទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: **LD១៨៣១២០០៤៨៣** ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នូវប្រាក់កម្ចីចំនួន USD **៤៣,000.00** (សែសិបបីពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែកដែលមានចំនួន USD**៥,៣៨៥.៨២**(ប្រាំពាន់បីរយប៉ែតសិបប្រាំដុល្លារអាមេរិក និងប៉ែតសិបពីរសេន)។ លុះក្រោយមកសហចុងចម្លើយបានព្រមព្រៀង



Scanned with CamScanner

ធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨ (សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ដោយបានកំណត់អត្រាការប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ នៃប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ផ្អែកតាមតារាងកាលវិភាគបង់ប្រាក់ ហើយត្រូវគណនាតាមចំនួនថ្ងៃដែលបានខកខាន។ ក្រោយពីបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ទាំងនេះរួចមក សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ទៅឱ្យដើមចោទតាមការកំណត់នូវប្រាក់ដើម និងការប្រាក់ គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

**គ.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច គ.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ដោយកំណត់អត្រាការប្រាក់ពិន័យក្នុងអត្រាចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ ក្នុងករណីដែលសហចុងចម្លើយបានយឺតយ៉ាវបង់សងប្រាក់ដើម និងការមកឱ្យដើមចោទ។ ការកំណត់នេះដែរ គឺស្របតាមប្រការ ២ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ចេញដោយក្រសួងយុត្តិធម៌ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតមិនត្រូវឱ្យលើសពីចំនួន២៧%(ម្ភៃប្រាំពីរភាគរយ) ក្នុង១(មួយ)ឆ្នាំ ឬស្មើនឹងចំនួន ២,២៥%(ពីរក្បៀសម្ភៃប្រាំភាគរយ) ក្នុង១(មួយ)ខែ ដែលគប្បីតុលាការទទួលស្គាល់ការកំណត់អត្រាប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយបង់សងអត្រាការប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ នៃប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨ (សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) ផ្អែកតាមតារាងវិភាគបង់ប្រាក់ ហើយត្រូវគណនាតាមចំនួនថ្ងៃដែលបានខកខានទៅឱ្យដើមចោទតាមការទាមទារ ដោយគិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

**ក-ការវិនិច្ឆ័យចំពោះការទាមទារប្រាក់ដើមលើកទី៣៖**

**ក.១-ការទទួលស្គាល់អង្គហេតុ៖**

-ដើមចោទ និងសហចុងចម្លើយទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: **LD១៩៣០៩០០២៩៩** ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវប្រាក់កម្ចីចំនួន **USD ២៤,000.00** (ម្ភៃបួនពាន់ដុល្លារអាមេរិកគត់) និងបានសងប្រាក់ដើមមួយផ្នែក ដែលមានចំនួន USD **២,១៣២.៥០**(ពីរពាន់មួយរយសាមសិបពីរដុល្លារអាមេរិក និងហាសិបសេន)។ លុះក្រោយមក សហចុងចម្លើយបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើម ចំនួន USD **២១,៨៦៧.៥០** (ម្ភៃមួយពាន់ប្រាំបីរយហុកសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) និងបានសងប្រាក់ដើមមួយផ្នែកទៀត



Scanned with CamScanner

ដែលមានចំនួន USD ២៤៧.៨៤(ពីររយសែសិបប្រាំពីរដុល្លារអាមេរិក និងប៉ែតសិបបួនសេន) ប្រាកដមែន។ ក្នុងនោះសហចុងចម្លើយឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] សាខន ពិតជានៅជំពាក់ប្រាក់ដើមចោទ [redacted] ចំនួន USD ២១,៦១៩.៦៦ (ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិប ប្រាំមួយសេន) ដែលមិនទាន់បានសង។

**ក.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច ក.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ធ្វើឡើងស្របតាមបញ្ញត្តិមាត្រា៥៧៩ និងមាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណី។ ភាគីទាំងពីរក៏បានទទួលស្គាល់ថា សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទ នូវប្រាក់ដើមចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) ដោយសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ គិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ ដែលជាហេតុនាំឱ្យដើមចោទធ្វើការទាមទារប្រាក់ដើម ដោយផ្អែកតាមការរំលាយកិច្ចសន្យា។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយសងប្រាក់ចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) ទៅឱ្យដើមចោទ ស្របតាមបញ្ញត្តិមាត្រា៤០៨ និងមាត្រា៤១១ នៃក្រមរដ្ឋប្បវេណី។

**ខ-ការវិនិច្ឆ័យអំពីការប្រាក់លើកទី៣៖**

**ខ.១-ការទទួលស្គាល់អង្គហេតុ៖**

ដើមចោទ និងសហចុងចម្លើយទទួលស្គាល់ថា ពិតជាបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវប្រាក់កម្ចីចំនួន USD ២៤,000.00(ម្ភៃបួនពាន់ដុល្លារអាមេរិកគត់) និងបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD ២១,៨៦៧.៥០(ម្ភៃមួយពាន់ប្រាំបីរយហុកសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) និងក្រោយមកបានសងប្រាក់ដើមចំនួន USD ២៤៧.៨៤(ពីររយសែសិបប្រាំពីរដុល្លារអាមេរិក និងប៉ែតសិបបួនសេន) ដោយមានភ្ជាប់ការប្រាក់ចំនួន: ១% (មួយភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)។ ក្នុងនោះដែរភាគីទាំងពីរក៏បានទទួលស្គាល់ថា ក្រោយពីបង្កើតកិច្ចសន្យាខ្ចីប្រាក់ទាំងនេះរួចមក សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចបង់ការប្រាក់ទៅឱ្យដើមចោទ គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ខ.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច ខ.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ និងដោយមានភ្ជាប់ការប្រាក់ក្នុងអត្រាចំនួន ១% (មួយភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)។ ការកំណត់អត្រាការប្រាក់នេះ គឺស្របតាមប្រការ ១ នៃប្រកាសលេខ ១២៨ កយ.



Scanned with CamScanner

ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ចេញដោយក្រសួងយុត្តិធម៌ ស្តីអំពីការប្រាក់ដែលត្រូវបានកម្រិតមិនត្រូវឱ្យលើសពីចំនួន១៨%(ដប់ប្រាំបីភាគរយ) ក្នុង១(មួយ)ឆ្នាំ ឬ១,៥%(មួយក្បៀសប្រាំភាគរយ) ក្នុង១(មួយ)ខែ ដែលគប្បីតុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ទៅតាមការព្រមព្រៀងរបស់គូភាគី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយបង់សងការប្រាក់ក្នុងអត្រាចំនួន ១% (មួយភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន USD**២១,៦១៩.៦៦**(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន ទៅឱ្យដើមចោទ។

**គ-ការវិនិច្ឆ័យអំពីប្រាក់ពិន័យលើកទី៣៖**

**គ.១-ការទទួលស្គាល់អង្គហេតុ៖**

-ដើមចោទ និងសហចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នូវប្រាក់កម្ចីចំនួន USD **២៤,000.00** (ម្ភៃបួនពាន់ដុល្លារអាមេរិកគត់) និងបានព្រមព្រៀងធ្វើវិសោធនកម្មកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ដែលមានប្រាក់ដើមចំនួន USD **២១,៨៦៧.៥០**(ម្ភៃមួយពាន់ប្រាំបីរយហុកសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) និងក្រោយមកបានសងប្រាក់ដើមចំនួន USD **២៤៧.៨៤**(ពីររយសែសិបប្រាំពីរដុល្លារអាមេរិក និងប៉ែតសិបបួនសេន) ដោយបានកំណត់អត្រាការប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ នៃប្រាក់ដើមចំនួន USD **២១,៦១៩.៦៦**(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) ផ្អែកតាមតារាងកាលវិភាគបង់ប្រាក់ ហើយត្រូវគណនាតាមចំនួនថ្ងៃដែលបានខកខាន។ ក្រោយពីបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ទាំងនេះរួចមក សហចុងចម្លើយខកខានមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ទៅឱ្យដើមចោទតាមការកំណត់នូវប្រាក់ដើម និងការប្រាក់ គិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

**គ.២-សេចក្តីសន្និដ្ឋាន៖**

ផ្អែកតាមការសរុបអង្គហេតុដែលបានទទួលស្គាល់នៅចំណុច គ.១ ខាងលើ តុលាការទទួលស្គាល់ថា ដើមចោទ និងសហចុងចម្លើយបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ ដោយកំណត់អត្រាការប្រាក់ពិន័យក្នុងអត្រាចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ ក្នុងករណីដែលសហចុងចម្លើយបានយឺតយ៉ាវបង់សងប្រាក់ដើម និងការមកឱ្យដើមចោទ។ ការកំណត់នេះដែរ គឺស្របតាមប្រការ ២ នៃប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ចេញដោយក្រសួងយុត្តិធម៌ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតមិនត្រូវឱ្យលើសពីចំនួន២៧%(ម្ភៃប្រាំពីរភាគរយ) ក្នុង១(មួយ)ឆ្នាំ ឬស្មើនឹងចំនួន ២,២៥%(ពីរក្បៀសម្ភៃប្រាំភាគរយ) ក្នុង១(មួយ)ខែ ដែលគប្បីតុលាការទទួលស្គាល់ការកំណត់អត្រាប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យសហចុងចម្លើយបង់



Scanned with CamScanner

សងអត្រាការប្រាក់ពិន័យចំនួន ២៤%(ម្ភៃបួនភាគរយ) ក្នុង១(មួយ)ឆ្នាំ នៃប្រាក់ដើមចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិប ប្រាំមួយសេន) ផ្អែកតាមតារាងវិភាគបង់ប្រាក់ ហើយត្រូវគណនាតាមចំនួនថ្ងៃដែលបានខកខានទៅឱ្យដើមចោទតាមការទាមទារ ដោយគិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

**ឃ-ការវិនិច្ឆ័យអំពីសំណងជម្ងឺចិត្ត និងការចំណាយផ្សេងៗ៖**

**ឃ.១-ការទទួលស្គាល់អង្គហេតុ៖**

ដើមចោទបានទាមទារប្រាក់ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗលើនីតិវិធីចំនួន៥.០០០,០០(ប្រាំពាន់)ដុល្លារអាមេរិកគត់ ពីសហចុងចម្លើយ ប៉ុន្តែដើមចោទពុំមានភស្តុតាងណាមួយបញ្ជាក់អំពីការខាតបង់ពេលវេលា និងការចំណាយផ្សេងៗឱ្យបានជាក់លាក់ឡើយ ហើយសហចុងចម្លើយក៏បានបដិសេធ និងច្រានចោលការទាមទារនៅត្រង់ចំណុចនេះ។

**ឃ.២-សេចក្តីសន្និដ្ឋាន៖**

តុលាការយល់ឃើញថា បើទោះបីជាដើមចោទពុំមានភស្តុតាងណាមួយបញ្ជាក់អំពីការទាមទារក្នុងចំណុច ឃ.១ ខាងលើ ប៉ុន្តែការមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់របស់សហចុងចម្លើយ ពិតជាបានធ្វើឱ្យដើមចោទមានការខាតបង់ពេលវេលា, ការប្រឹក្សាផ្នែកច្បាប់, ការចំណាយទៅលើសេវាកម្មមេធាវី និងការចំណាយផ្សេងៗនៅក្នុងដំណើរការរឿងក្តីទាមទារប្រាក់នេះ ប្រាកដមែន។ ហេតុដូច្នេះ គប្បីតុលាការពិនិត្យ និងពិចារណាការចំពោះការទាមទាររបស់ដើមចោទ ស្របតាមមាត្រា៤០១ នៃក្រមរដ្ឋប្បវេណី។

**ង-ការវិនិច្ឆ័យអំពីការសុំឱ្យសាលក្រមមានអានុភាពអនុវត្តបណ្តោះអាសន្ន៖**

ការទាមទាររបស់ដើមចោទបានស្នើសុំឱ្យតុលាការប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះ អាសន្នបាន។ តុលាការយល់ឃើញថា ការអនុវត្តជាបណ្តោះអាសន្នលើសាលក្រម អាចអនុវត្តបានតែលើការទាមទារស្តីពីប្រាក់ដើមតែប៉ុណ្ណោះ ព្រោះជាការទាមទារពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យសម្បត្តិ ដែលមានលក្ខណៈស្របទៅនឹងមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ រីឯការទាមទារឱ្យអនុវត្តជាបណ្តោះអាសន្នលើចំណុចផ្សេង ក្រៅពីប្រាក់ដើម ជាការទាមទារមិនត្រឹមត្រូវនោះទេ ដោយហេតុថាការទាមទារនោះពុំបានកំណត់ពីចំនួនទឹកប្រាក់ច្បាស់លាស់ និងជាការដាក់បន្ទុកបន្ថែមទៅដល់សហចុងចម្លើយ។ ដូច្នេះ គប្បីតុលាការពិចារណា និងសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្នលើសាលក្រម ត្រង់ចំណុចស្តីពីប្រាក់ដើមតែប៉ុណ្ណោះ ដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគ ស្របតាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ច-អំពីប្រាក់ប្រដាប់ក្តី៖**

ផ្អែកតាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ដោយហេតុថា តុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ ព្រោះការប្តឹងទាមទារប្រាក់នេះ គឺកើត



Scanned with CamScanner

ចេញពីកំហុសរបស់សហចុងចម្លើយ ដែលបានបំពានក្នុងការអនុវត្តកាតព្វកិច្ចសងប្រាក់ទៅឱ្យដើមចោទ ហេតុដូច្នេះ គប្បីតុលាការសម្រេចអំពីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **សារឿន** និងប្រពន្ធឈ្មោះ [redacted] **សាខន** រួមគ្នាសងប្រាក់ទៅឱ្យដើមចោទ **ធនាគារ**[redacted] ដែលមានអ្នកតំណាងឈ្មោះ [redacted] **សម្បត្តិ** និងឈ្មោះ [redacted] **វណ្ណា** និងអ្នកតំណាងដោយអាណត្តិគឺលោកមេធាវី [redacted] ដូចខាងក្រោម:

១-១-ក-ប្រាក់ដើមចំនួន USD ២០,៧៦៥.៤១(ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន)។

១-១-ខ-ការប្រាក់ចំនួន USD ៤,៦៩៦.៥៤(បួនពាន់ប្រាំមួយរយកៅសិបប្រាំមួយដុល្លារអាមេរិក និងហាសិបបួនសេន) នៃប្រាក់ដើមចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) គិតចាប់ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ តាមកិច្ចសន្យាខ្ចីប្រាក់លេខ: LD១៧១៨៦០០៧៩០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧។

១-១-គ-ប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** នៃប្រាក់ដើមចំនួន USD ២០,៧៦៥.៤១ (ម្ភៃពាន់ប្រាំពីររយហុកសិបប្រាំដុល្លារអាមេរិក និងសែសិបមួយសេន) លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន។

១-២-ក-ប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន)។

១-២-ខ-ការប្រាក់ចំនួន 0.៩0%**ក្នុងមួយខែ** នៃប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) គិតចាប់ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន តាមកិច្ចសន្យាខ្ចីប្រាក់លេខ: LD១៨៣១២០០៤៨៣ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១-២-គ-ប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** នៃប្រាក់ដើមចំនួន USD ៣៧,៦១៤.១៨(សាមសិបប្រាំពីរពាន់ប្រាំមួយរយដប់បួនដុល្លារអាមេរិក និងដប់ប្រាំបីសេន) លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន ផ្អែកតាមតាមកិច្ចសន្យាខ្ចីប្រាក់លេខ: LD១៨៣១២០០៤៨៣ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១-៣-ក-ប្រាក់ដើមចំនួន USD ២១,៦១៩.៦៦(ម្ភៃមួយពាន់ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន)។



Scanned with CamScanner

១-៣-ខ-ការប្រាក់ចំនួន **១%ក្នុងមួយខែ** នៃប្រាក់ដើមចំនួន USD **២១,៦១៩.៦៦**(ម្ភៃមួយពាន់ ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) គិតចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

១-៣-គ-ទាមទារប្រាក់ពិន័យចំនួន **២៤%ក្នុងមួយឆ្នាំ** នៃប្រាក់ដើមចំនួន USD **២១,៦១៩.៦៦**(ម្ភៃមួយពាន់ ប្រាំមួយរយដុល្លារអាមេរិក និងហុកសិបប្រាំមួយសេន) លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង គិតចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃអនុវត្តសងប្រាក់គ្រប់ចំនួន ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់(ឥណទានអាជីវកម្មខ្នាតតូច)លេខ: LD១៩៣០៩០០២៩៩ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

២-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **សារឿន** និងប្រពន្ធឈ្មោះ [redacted] **សាខន** បង់ប្រាក់សេវាពិគ្រោះផ្លូវច្បាប់, ការខាតបង់ពេលវេលា និងប្រាក់ជំងឺចិត្តចំនួន ២,០០០,០០០(ពីរលាន)រៀល។

៣-សាលក្រមនេះមានអានុភាពក្នុងការអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច៖

-១-១-ក នៃសេចក្ដីសម្រេចនេះ។

-១-២-ក នៃសេចក្ដីសម្រេចនេះ។

-១-៣-ក នៃសេចក្ដីសម្រេចនេះ។

៤-សហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

សាលក្រមនេះបានបញ្ចប់នីតិវិធីនៃការទាញហេតុផលផ្ទាល់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង០៨ និង៣០នាទី ព្រឹក និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោងប្រាំបួន និងសាមសិបនាទី ព្រឹក ចំពោះមុខអ្នកតំណាងឲ្យដើមចោទ [redacted] ដែលមានអ្នកតំណាងឈ្មោះ [redacted] **សម្បត្តិ** និងឈ្មោះ [redacted] **វណ្ណា:** និងអ្នកតំណាងដោយអាណត្តិគឺលោកមេធាវី [redacted] និងលោក [redacted] និងសហចុងចម្លើយឈ្មោះ [redacted] **សារឿន**, ឈ្មោះ [redacted] **សាខន** និងអ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយគឺលោកមេធាវី [redacted] ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ហត្ថលេខា និងត្រា**

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ក្រចេះ, ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner